ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០២៥/២២ ក.ប/ស.ណ.ន.2.ល

## សេចក្តីណែនាំ
## ស្តីពី
## ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៦ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០២២

យោងលិខិតលេខ១៦១សណជ.អវ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងសារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំខួបអនុស្សាវរីយ៍លើកទី១៣៦ ទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ ក្រោមប្រធានបទ "សន្តិភាព សុខភាព និងសន្តិសុខការងារ" ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដូចខាងក្រោម៖

- គ្រប់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវសហការជាមួយរដ្ឋបាលរាជធានី ខេត្ត អង្គការវិជ្ជាជីវៈ ព្រមទាំងនិយោជក រៀបចំពិធីសំណេះសំណាលជាមួយកម្មករនិយោជិត សហជីព និងតំណាងមន្ត្រីរាជការ គ្រូបង្រៀន រំលឹកខួបអនុស្សាវរីយ៍លើកទី១៣៦ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០២២ តាមស្ថានភាពជាក់ស្តែង
- ម្ចាស់រោងចក្រ សហគ្រាស ត្រូវស្វ័យរៀបចំក្នុងកម្រិតរោងចក្រ សហគ្រាស ទៅតាមទីកន្លែង និងកម្មវិធីរៀងៗខ្លួន ប្រកបដោយបរិយាកាសរីករាយស្និទ្ធស្នាល។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសង្ឃឹមយ៉ាងមុតមាំថា ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត និងម្ចាស់ ឬនាយករោងចក្រ សហគ្រាស នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ៩រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២២
រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល:**
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា
- សមាគមផលិតផលធ្វើដំណើរ និងស្បែកនៅកម្ពុជា
  *"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"*
- ឯកសារ កាលប្បវត្តិ